មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
CAMBODIAN CENTER FOR HUMAN RIGHTS

# សេចក្តីថ្លែងការណ៍

ភ្នំពេញ ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០០៩

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា សោកស្តាយចំពោះ ចំណាត់ការរបស់តុលាការខេត្តស្វាយរៀងសំរេចឃុំខ្លួនប្រជាពលរដ្ឋពីររូប

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានការសោកស្តាយយ៉ាងខ្លាំងចំពោះចំណាត់ការរបស់តុលាការខេត្តស្វាយរៀង ដែលសំរេចធ្វើការឃុំខ្លួនប្រជាពលរដ្ឋចំនួនពីររូប កាលពីថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៩ ពីបទចោទប្រកាន់បំផ្លាញដោយចេតនា នូវបង្គោលតំរុយព្រំដែន ខ្មែរនិងវៀតណាម កាលពីថ្ងៃទី២៥ តុលា កន្លងទៅ។

ប្រជាពលរដ្ឋទាំងពីររូប ដែលត្រូវឃុំខ្លួននោះរួមមានឈ្មោះ មាស ស្រី អាយុ៣៨ឆ្នាំ ជាស្ត្រីម៉េម៉ាយ មានកូនចំនួន ២ នាក់នៅក្នុងបន្ទុក មានមុខរបរធ្វើស្រែចំការ និងឈ្មោះ ព្រំ ជា អាយុ ៤៨ឆ្នាំ មានកូនចំនួន៤នាក់នៅក្នុងបន្ទុកមានមុខរបរធ្វើស្រែចំការផងដែរ។ អ្នកទាំងពីររស់នៅ ក្នុងភូមិកោះក្បានស្ពាន ឃុំសំរោង ស្រុកចន្ទ្រា ខេត្តស្វាយរៀង ត្រូវតុលាការសំរេចឃុំខ្លួន បន្ទាប់ពីបានកោះហៅអ្នកទាំងពីរមកសាកសួរពីករណីចោទ ប្រកាន់បំផ្លាញទ្រព្យសម្បត្តិសាធារណៈ។

កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៩ កន្លងទៅក្នុងឱកាសដែលលោក សម រង្ស៊ី ដង្ហែអង្គកឋិនទានចូលប្រគេនព្រះសង្ឃក្នុងវត្តអង្គរំដិញក្នុងស្រុកចន្ទ្រា ខេត្តស្វាយរៀង។ ឆ្លៀតក្នុងឱកាស នោះលោក សម រង្ស៊ី អមដំណើរដោយតំណាងរាស្ត្រមួយចំនួនមកពីគណបក្សរបស់លោក និងប្រជាពលរដ្ឋបានចុះត្រួតពិនិត្យមើលភូមិសាស្ត្រតំបន់តាមបណ្តោយព្រំដែន ខ្មែរនិងវៀតណាម។ ប្រជាពលរដ្ឋនៅស្រុកចន្ទ្រា រួមមានអ្នកស្រី មាស ស្រី និង លោក ព្រំ ជា បានចង្អុលបង្ហាញអំពីបង្គោលឈើចំនួន៦ដើមដាំនៅក្នុងដីស្រែរបស់គាត់ ដែលបង្គោលនេះត្រូវបានចាត់ទុកជាបង្គោលព្រំដែនលេខ១៨៥ រវាងប្រទេសខ្មែរនិងវៀតណាម។ ដោយលើកហេតុផលថា បង្គោលទាំងនេះស្ថិតនៅក្នុងដីស្រែរបស់ពួកគាត់ ទើបអ្នកភូមិទាំងនេះបានដកបង្គោលទាំងនេះចោល។

យោងតាមការស៊ើបអង្កេត តំណាងរាស្ត្រជាច្រើនមកពីគណបក្សសមរង្ស៊ី រួមមានលោក សម រង្ស៊ី លោកអេង ឆៃអ៊ាង លោកសុន ឆ័យ មន្ត្រីនានាតាមមូលដ្ឋាន រួមទាំងប្រជាពលរដ្ឋជាច្រើននាក់បានអះអាងថា បង្គោលព្រំដែនទាំងនោះពិតជាបានបោះរំលោភចូលក្នុងទីតាំងភូមិសាស្ត្រដីស្រែរបស់ប្រជាពលរដ្ឋទាំងនោះ ក៏ដូចជាដែនអធិបតេយ្យភាពរបស់ប្រទេសកម្ពុជាមែន។

The Cambodian Center for Human Rights, # 798, St. 99, Sangkat Boeung Trabek, Khan Chamkarmorn, Phnom Penh, Cambodia.
Tel: 023 726 901, Fax. 023 726 902, Email: info@cchrcambodia.org website: www.cchrcambodia.org

ប្រជាពលរដ្ឋដែលរស់នៅតំបន់នោះតាំងពីយូរមកហើយ បានលើកឡើងថា ទីតាំងព្រំប្រទល់រវាងប្រទេសទាំងពីរគឺស្ថិតនៅចំងាយប្រមាណជា២គីឡូម៉ែត្រពីទីតាំងខាងលើ។ ម្យ៉ាងទៀត ទាក់ទងនឹងការមកបោះបង្គោលថ្មីទាំងនេះ អាជ្ញាធរដែលមានសមត្ថកិច្ចទាក់ទងនឹងព្រំដែនរបស់ប្រទេសទាំងពីរខ្មែរនិងវៀតណាម បានធ្វើសកម្មភាពដោយស្ងាត់ៗមិនបានផ្តល់ដំណឹងដល់ប្រជាពលរដ្ឋ ក៏ដូចជាអ្នកសារព័ត៌មាននិងប្រជាពលរដ្ឋទូទៅ ដែលទង្វើនេះឆ្លុះបញ្ចាំងពីភាពគ្មានតម្លាភាព នៅក្នុងបញ្ហាវាស់វែងព្រំដែននេះ។

គេសង្កេតមើលឃើញថា ចំណាត់ការរបស់តុលាការខេត្តស្វាយរៀង គឺគ្រាន់តែជាការទទួលរងនូវឥទ្ធិពលនយោបាយប៉ុណ្ណោះ។ ទង្វើនេះ ក៏ឆ្លុះបញ្ចាំងអំពីការរំលោភទៅលើសិទ្ធិមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលទទួលបាននូវការរស់នៅមានជីវភាព សមរម្យ ដូចមានចែងនៅក្នុងមាត្រាទី២៥ នៃសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស "មនុស្សគ្រប់រូប មានសិទ្ធិទទួលបានកំរិតជីវភាពគ្រប់គ្រាន់ដើម្បីធានាសុខភាពរបស់ខ្លួននិង គ្រួសារ រួមមានចំណីអាហារ សម្លៀកបំពាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងសេវាសង្គម កិច្ចការចាំបាច់ផ្សេងៗទៀត។"

ប្រជាពលរដ្ឋទាំងនេះពឹងផ្អែកលើ ការធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិត។ ប្រសិនបើដីស្រែរបស់ពួកគាត់ត្រូវបាត់បង់នោះ នោះនឹងធ្វើឲ្យគាត់ត្រូវប្រឈមនឹងកង្វះខាតផ្នែកជីវភាព ដែលឈានទៅ រកការធ្លាក់យ៉ាងជ្រៅទៅក្នុងភាពក្រីក្រ។

ម្យ៉ាងទៀត អធិបតេយ្យភាពរបស់ខ្មែរមិនអាចរំលោភបាននោះទេ។ មាត្រាទី២ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា "បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជា មិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួន ដែលមានកំណត់ក្នុងផែនទីខ្នាត១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ នៅចន្លោះឆ្នាំ ១៩៦៣-១៩៦៥។

សំរាប់ព័ត៌មានបន្ថែមសូមទាក់ទង
លោក **អ៊ូ វីរៈ** ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
លេខទូរសព្ទ: ០១២ ៨០ ៨០ ៥១

លោក**អឿ ណារិន** អ្នកស្រាវជ្រាវ
លេខទូរសព្ទ: ០១២ ៦០ ៦១ ១៨